អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា
Kampuchea Action to Promote Education (KAPE)

# សេចក្តីណែនាំ និងឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ

## ឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ

អ្នកដេញថ្លៃទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារភស្តុតាង បង្ហាញពីលក្ខណៈសម្បត្តិរបស់ខ្លួនមានដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះឈ្មោះក្រុមហ៊ុន ឬអាជីវកម្ម ក្នុងបញ្ជីក្រសួងពាណិជ្ជកម្ម (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- វិញ្ញាបនបត្រប្រកបអាជីវកម្ម ចេញដោយក្រសួងពាក់ព័ន្ធ (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- ប័ណ្ណប៉ាតង់ប្រចាំឆ្នាំ២០២៤ (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់
- ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាពបច្ចេកទេស និងបទពិសោធន៍ក្នុងការផ្គត់ផ្គង់របស់ខ្លួន ០១ ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ ឬលិខិតឆ្លងដែន (ថតចម្លង ចាំបាច់ត្រូវដាក់) ០១ ច្បាប់

ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ ទាំងអស់ដែលមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា៖ ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ ដែលបានចូលរួមធ្វើការដេញថ្លៃជាក្រុមហ៊ុនមានសម្ព័ន្ធភាពតែមួយ ឬប្រភពតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ។

<u>បញ្ជាក់៖</u>

- ការទទួលឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ ចាប់ពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង ៥:០០នាទីល្ងាចជាកំហិត តាមរយៈសារអេឡិចត្រូនិច (អ៊ីម៉ែលជូនភ្ជាប់) ព្រមទាំងចម្លងជូន (CC) មកអ្នកពាក់ព័ន្ធទាំងអស់។
- ប្រជុំតម្រង់ទិសអំពីនិតិវិធីនៃការបំពេញសម្រង់តម្លៃសម្រាប់ចូលរួមដេញថ្លៃដោយផ្ទាល់នឹងប្រព្រឹត្តិទៅ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង ០៩:០០នាទីព្រឹក ដែលមានអាសយដ្ឋាននៅការិយាល័យរង សាលារៀនជំនាន់ថ្មី (ស្ថិតនៅក្នុងបរិវេណវិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ) យើងមិនទទួលខុសត្រូវក្នុងការបើកកញ្ចប់ដេញថ្លៃទេ ប្រសិនគ្រប់ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ មិនអញ្ជើញមកចូលរួមស្តាប់ការណែនាំ និងការតម្រង់ទិសក្នុងការជំនួយស្មារតីនៃការចូលរួមដេញថ្លៃ មានដូចជា៖ (ប្លង់ រូបភាព ទីតាំងសាលារៀន និងផ្សេងទៀត)។
- រាល់ឯកសារសម្រង់តម្លៃ (ត្រូវបញ្ចូលពន្ធអាករលើតម្លៃបន្ថែម ១០%) និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ត្រូវច្រកក្នុងស្រោមបិទជិត ដោយមានចុះហត្ថលេខា និងបោះត្រារបស់ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ នៅលើស្រោមសំបុត្ររួចបញ្ជូនមកការិយាល័យរដ្ឋបាល នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) ចាប់ពី ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៤ ដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង ០៤:០០នាទីល្ងាចជាកំហិត ដែលមានអាសយដ្ឋាននៅការិយាល័យរង សាលារៀនជំនាន់ថ្មី (ស្ថិតនៅក្នុងបរិវេណវិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ) ហើយមិនអនុញ្ញាតឱ្យដាក់មកតាមរយៈសារអេឡិចត្រូនិច (អ៊ីមែល) បានជាដាច់ខាត។
- គ្រប់ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ទាំងអស់ អាចចូលរួមដេញថ្លៃបាន លុះត្រាតែក្រុមហ៊ុន និងអ្នកម៉ៅការសំណង់នោះបាន

**ចុះមើលទីតាំងសាលារៀនគោលដៅដោយផ្ទាល់ ដើម្បីងាយស្រួលធ្វើការប្រៀបធៀបជាមួយ BoQ ដែលបានផ្តល់ដោយគម្រោង ហើយមានការបោះត្រាទទួលស្គាល់ពីនាយក/នាយករង សាលារៀនគោលដៅថា ពិតជាបានចុះពិនិត្យមើលត្រឹមត្រូវពិតប្រាកដមែន។**

- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ ដែលមិនបានដាក់ជូនមកការិយាល័យរដ្ឋបាលរបស់អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ទាន់ពេលវេលាទេ ត្រូវចាត់ទុកជាអាសាបង់។
- អ្នកចូលរួមដេញថ្លៃទាំងអស់ ត្រូវអញ្ជើញមកចូលរួមប្រជុំស្តាប់ការបើកកញ្ចប់ដេញថ្លៃឱ្យទាន់ពេលវេលា។ ប្រសិនបើអ្នកដេញថ្លៃណាដែលមិនបានចូលរួមប្រជុំបើកកញ្ចប់ដេញថ្លៃទាន់ពេលវេលា ឬក៏អវត្តមានក្នុង(រយៈពេល១៥នាទី)ឯកសារដាក់ដេញថ្លៃនោះមិនអនុញ្ញាតដាក់បញ្ចូលក្នុងការបើកឡើយ។
- ចំពោះអ្នកចូលរួមប្រជុំការបើកបញ្ចប់ឯកសារដេញថ្លៃទាំងអស់ដែលជាអ្នកមកតំណាងក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ត្រូវមានលិខិតផ្ទេរសិទ្ធិ ដែលមានចុះហត្ថលេខាត្រឹមត្រូវពីប្រធានក្រុមហ៊ុន និងម្ចាស់អ្នកម៉ៅការសំណង់។
- យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរកាលបរិច្ឆេទនៃការបើកកញ្ចប់ដេញថ្លៃ ប្រសិនបើមានការចាំបាច់ ហើយយើងខ្ញុំនឹងជូនដំណឹងជាមុនទៅក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ ដែលបានផ្ញើឯកសារដេញថ្លៃមក។
- រាល់ឯកសារដែលដាក់មកហើយ គណៈកម្មការយើងខ្ញុំមិនប្រគល់ជូនត្រឡប់ទៅវិញទេ។


- *Head Offices: Provincial Teacher Training College of Kampong Cham Kampong Cham Town, Kampong Cham Province.*
- *Mailing Address: PO Box1621, Post Office, P. Penh. Tel.: 042-941-481, 042- 941-918; E-mail: kape@kapekh.org; www.kapekh.org*